ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ ០៩៩ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់វិធាននៃការអនុវត្តកសិកម្មល្អ ក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់

---

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី.១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារ ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញ អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស្រូវត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ សេចក្តីសម្រេចរបស់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន លើកទី ២៨ នាថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នៅប្រទេសសិង្ហបុរី
- បានឃើញ ប្រកាសលេខ ៣៣៤ ប្រក.កសក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**ប្រការ ១:** ប្រកាសនេះ សំដៅដាក់ឱ្យប្រើប្រាស់នូវវិធាននៃការអនុវត្តកសិកម្មល្អ (Good Agricultural Practices – GAP) ក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ ដើម្បីលើកកម្ពស់សុវត្ថិភាពចំណីអាហារ ទប់ស្កាត់ការប៉ះពាល់បរិស្ថាន ការពារសុខភាព សុវត្ថិភាព និងសុខុមាលភាពអ្នកផលិត ព្រមទាំងលើកកម្ពស់គុណភាពកសិផល និងធ្វើឱ្យប្រសើរឡើងដល់សុខដុមនីយកម្មនៃស្តង់ដារផលិតផល និងសម្របសម្រួលពាណិជ្ជកម្មផ្លែឈើ និងបន្លែស្រស់នៅលើទីផ្សារ ។

**ប្រការ ២:** វិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ មិនរាប់បញ្ចូលនូវផលិតកម្មនៃផលិតផលកសិកម្មដទៃទៀតឡើយ ។

**ប្រការ ៣:** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើការដាំដុះ ឬ ធ្វើពាណិជ្ជកម្ម ផ្លែឈើ និងបន្លែស្រស់ ត្រូវបានទទួលការអប់រំ និងជំរុញឱ្យអនុវត្ត និងគោរពតាមវិធាននៃការអនុវត្តកសិកម្មល្អ ដើម្បីធានាបានថា ផលិតផលទាំងនោះ មានគុណភាពល្អ និងមានសុវត្ថិភាពក្នុងការបរិភោគ ។

វិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៤:** អគ្គនាយកដ្ឋានកសិកម្មត្រូវទទួលខុសត្រូវរៀបចំអនុវត្តប្រព័ន្ធយន្តការគ្រប់គ្រងការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ និងជាអង្គភាពគ្រប់គ្រង និងចេញនូវវិញ្ញាបនបត្រអនុលោមភាពតាមវិធាននៃការអនុវត្តផលិតកម្មល្អ (Certificate of GAP Compliance) ។

**ប្រការ ៥:** ប្រកាស ឬសេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦:** អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១០

រ ដ្ឋ ម ន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ